គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

# កិច្ចសន្យាបញ្ញើពិសេស

ឧទ្ទេសនាមដោយ ៖ មេធាវី យឹម វិស្សុត

មេធាវីមាស សារិន



ប្រព្រឹត្តនៅថ្ងៃទី០៩ ខែ មិថុនា ឆ្នាំ២០១៦

# មាតិកា

សញ្ញាណទូទៅនៃបញ្ញើ

១.និយមន័យកិច្ចសន្យាបញ្ញើ

២.កម្មវត្ថុនៃកិច្ចសន្យាបញ្ញើ

៣.ប្រភេទនៃកិច្ចសន្យាបញ្ញើ

៤. ការបង្កើតកិច្ចសន្យាបញ្ញើពិសេសនិងអានុភាព

- ៤.១.កិច្ចសន្យាបញ្ញើដោយរួមបញ្ចូលគ្នា
- ៤.២.កិច្ចសន្យាបញ្ញើបរិភោគ
- ៤.៣.កិច្ចសន្យាវិសុណ្ឌាប័ន
- ៤.៤.កិច្ចសន្យាបញ្ញើជាប្រាក់នៅធនាគារ

៥.ករណីសិក្សា

# សញ្ញាណទូទៅ

*បញ្ញត្តិស្តីពីបញ្ញើ មានចែងក្នុង គន្ថីទី៥ ជំពូកទី១០ នៃក្រមរដ្ឋប្បវេណី*

→ ទំនាក់ទំនងបញ្ញើមានការវិវត្ត

→ កិច្ចសន្យាបញ្ញើជាច្រើនត្រូវបានបង្កើតឡើង

→ ច្បាប់និងបទដ្ឋានគតិយុត្តត្រូវបានបញ្ញត្តិឡើង

# ១. និយមន័យ (ម.៦៦៩.១ ក.រ)

- មានការព្រមព្រៀងរវាងអ្នកផ្ញើនិងអ្នកទទួលបញ្ញើ
- មានការប្រគល់និងទទួលវត្ថុបញ្ញើ
- មានការរក្សាទុកវត្ថុបញ្ញើ (កាន់កាប់និង គ្រប់គ្រង)
- អំឡុងពេលកំណត់
- ការសងវត្ថុបញ្ញើងដែលវិញ

## ២. កម្មវត្ថុនៃកិច្ចសន្យាបញ្ញើ (ម.៦៦៩ ក.រ)

- ជាវត្ថុៈភាគច្រើនជាចលនវត្ថុមានដូចជាគ្រឿងអលង្ការ ប្រាក់កាស ទំនិញគ្រឿងឧបភោគបរិភោគ គ្រឿង សង្ហារិម គ្រឿងយន្ត និងសត្វ។ល។

- អចលនវត្ថុក៏អាចជាកម្មវត្ថុបញ្ញើដែរ (ករណីកម្រ) ។

- មនុស្សមិនអាចជាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើទេ ។

# ៣. ប្រភេទនៃកិច្ចសន្យាបញ្ញើ

- កិច្ចសន្យាបញ្ញើធម្មតា (ម.៦៦៩-៦៨៨ ក.រ)
- កិច្ចសន្យាបញ្ញើដោយរួមបញ្ចូល (ម.៦៨៩ ក.រ) (ពិសេស)
- កិច្ចសន្យាបញ្ញើបរិភោគ (ម.៦៩០-៦៩១ ក.រ) (ពិសេស)
- កិច្ចសន្យាវិសុណ្ឌាប័ន (ម.៦៩២-៦៩៨ ក.រ) (ពិសេស)
- កិច្ចសន្យាបញ្ញើជាប្រាក់នៅធនាគារ (ពិសេស)

# ៤. ការបង្កើតកិច្ចសន្យាបញ្ញើពិសេសនិងអានុភាព

## ៤.១.បញ្ញើដោយរួមបញ្ចូលគ្នា (ម.៦៨៩. ក.រ)

- ការព្រមព្រៀងរវាងអ្នកផ្ញើច្រើននាក់និងអ្នកទទួលបញ្ញើ
- រក្សាទុកវត្ថុច្រើនមានប្រភេទនិងគុណភាពដូចគ្នាដោយរួមបញ្ចូលគ្នា
- ការប្រគល់នាំឲ្យបង្កើតអានុភាព (ម.៦៧០.១ ក.រ)
- ការសងវត្ថុបញ្ញើវិញដែលមានគុណភាពឬប្រភេទនិងចំនួនដូចគ្នា

# ឧទាហរណ៍៤.១.បញ្ញើដោយរួមបញ្ចូលគ្នា (ម.៦៨៩.ក.រ)



# ៤.១.១.ភាពខុសគ្នារវាងបញ្ញើដោយរួមបញ្ចូលគ្នា និងបញ្ញើធម្មតា

| | បញ្ញើដោយរួមបញ្ចូលគ្នា | បញ្ញើធម្មតា |
|---|---|---|
| និយមន័យ | • មានអ្នកផ្ញើច្រើននាក់ យកវត្ថុដែលមានប្រភេទដូចគ្នាទៅផ្ញើនឹងអ្នកទទួលបញ្ញើឲ្យរក្សាទុកដោយរួមបញ្ចូលគ្នា។ | • មានអ្នកផ្ញើម្នាក់ យកវត្ថុបញ្ញើដែលបានកំណត់ជាក់លាក់ ទៅផ្ញើនឹងអ្នកទទួលបញ្ញើ។ |
| | • វត្ថុបញ្ញើដោយរួមបញ្ចូលគ្នាជាកម្មសិទ្ធិអវិភាគត្រូវប្រគល់វិញតាមសមាមាត្រនៃចំនួនវត្ថុរបស់អ្នកផ្ញើម្នាក់ៗ ។ | • វត្ថុបញ្ញើធម្មតាជាកម្មសិទ្ធិផ្តាច់មុខ ត្រូវប្រគល់សងវត្ថុបញ្ញើដដែលទៅអ្នកផ្ញើវិញ។ |

# ៤.១.២.ហេតុអ្វីបានជាត្រូវផ្ញើដោយរួមបញ្ចូលគ្នា?

- សន្សំសំចៃទីកន្លែងសម្រាប់រក្សាទុក
- ចំណាយតិចសម្រាប់សេវារក្សាទុក
- ងាយស្រួលគ្រប់គ្រងអំពីហានិភ័យផ្សេងៗ

# ៤.២. កិច្ចសន្យាបញ្ញើបរិភោគ (ម.ត.៦៩០ក.រ)

- ការព្រមព្រៀងរវាងអ្នកផ្ញើនិងអ្នកទទួលបញ្ញើ
- ការប្រគល់នាំឲ្យបង្កើតអានុភាព (ម.៦៧០.១ ក.រ)
- អ្នកទទួលបញ្ញើអាចបរិភោគវត្ថុបញ្ញើបាន
- អំឡុងពេលកំណត់សងវត្ថុ
- ករណីយកិច្ចសងវត្ថុបញ្ញើមានប្រភេទនិងចំនួនដូចគ្នា

# ឧទាហរណ៍.៤.២. បញ្ញើបរិភោគ (ម.ត.៦៨០ក.រ)



## ៤.២.២. ភាពខុសគ្នារវាងបញ្ញើធម្មតា បញ្ញើដោយរួមបញ្ចូលគ្នា និង បញ្ញើបរិភោគ 7

| | បញ្ញើធម្មតា | បញ្ញើដោយរួមបញ្ចូលគ្នា | បញ្ញើបរិភោគ |
|---|---|---|---|
| ភាពខុសគ្នា | • មានអ្នកផ្ញើម្នាក់ យកវត្ថុបញ្ញើដែលបានកំណត់ជាក់លាក់ទៅផ្ញើនឹងអ្នកទទួលបញ្ញើ។ | • មានអ្នកផ្ញើច្រើននាក់ យកវត្ថុដែលមានប្រភេទដូចគ្នាទៅផ្ញើនឹងអ្នកទទួលបញ្ញើឲ្យរក្សាទុកដោយរួមបញ្ចូលគ្នា។ | • មានអ្នកផ្ញើម្នាក់យកវត្ថុបញ្ញើទៅផ្ញើនិងអ្នកផ្ញើ |
| | • អ្នកផ្ញើចំណាយសោហ៊ុយថែរក្សាវត្ថុបញ្ញើ | • អ្នកផ្ញើចំណាយសោហ៊ុយថែរក្សាវត្ថុបញ្ញើ | • អ្នកទទួលបញ្ញើអាចបរិភោគវត្ថុបញ្ញើ ទទួលផលពីវត្ថុបញ្ញើ និងចំណាយថ្លៃថែរក្សាវត្ថុបញ្ញើដោយខ្លួនឯង |
| | • អ្នកទទួលបញ្ញើត្រូវប្រគល់សងវត្ថុបញ្ញើដដែលទៅអ្នកផ្ញើវិញ។ | • អ្នកទទួលបញ្ញើមានសិទ្ធិប្រគល់វត្ថុបញ្ញើដែលបានរួមបញ្ចូលគ្នាទៅអ្នកផ្ញើនីមួយៗតាមសមាមាត្រនៃចំនួនវត្ថុរបស់ផ្ញើម្នាក់ដែលបានផ្ញើតាំងពីដំបូង។ | • អ្នកទទួលបញ្ញើមានសិទ្ធិសងវត្ថុបញ្ញើជំនួសដែលមានប្រភេទ និងចំនួនដូចគ្នាបាន។ |

# ៤.៣.កិច្ចសន្យាវិសុណ្ឌាប័ន (ម.៩៦៨២ក.រ)

- ការព្រមព្រៀងរវាងអ្នកផ្ញើច្រើននាក់និងវិសុណ្ឌាបនិក
- វត្ថុបញ្ញើជាកម្មវត្ថុនៃវិវាទកម្មសិទ្ធិឬសិទ្ធិកាន់កាប់
- ការប្រគល់ពីអ្នកកាន់កាប់ទៅតតិយជន
- ការសងវត្ថុបញ្ញើទៅអ្នកទទួលបានសិទ្ធិកម្មសិទ្ធិជាស្ថាពរ

# ឧទាហរណ៍នៃកិច្ចសន្យាវិសុណ្ឋាប័ន (ម.ត៦៩២ក.រ)



# ឧទាហរណ៍នៃកិច្ចសន្យាវិសុណ្ឋាប័ន (ម.ត៦៩៣ និង៦៩៤ក.រ)



# ៤.៤. បញ្ញើជាប្រាក់នៅធនាគារ

៤.៤.១.ការបង្កើតកិច្ចសន្យាបញ្ញើជាប្រាក់និងអានុភាព

៤.៤.២.ប្រភេទបញ្ញើជាប្រាក់នៅធនាគារ

# ៤.៤.១.ការបង្កើតបញ្ញើជាប្រាក់នៅធនាគារ

- ការព្រមព្រៀងរវាងអ្នកផ្ញើ និងធនាគារ
- វត្ថុជាកម្មវត្ថុនៃបញ្ញើជាប្រាក់
- ធនាគារអាចបរិភោគឬអាស្រ័យផលលើវត្ថុបញ្ញើបាន (CC690)
- អ្នកផ្ញើអាចទទួលបានផលពីប្រាក់ឬការប្រាក់ (CC691)
- ការសងវត្ថុបញ្ញើតាមប្រភេទនិងចំនួនប្រាក់ដែលបានផ្ញើ (CC690)

# ឧទាហរណ៍ការបង្កើតបញ្ញើជាប្រាក់នៅធនាគារ



# ៤.៤.២. ប្រភេទនៃបញ្ញើជាប្រាក់នៅធនាគារ

7

(១).បញ្ញើសន្សំ Saving Deposit

(២).បញ្ញើមានពេលកំណត់ Fix Deposit

(៣).បញ្ញើគ្មានកាលកំណត់ Current Deposit

(៤).អាចមានបញ្ញើផ្សេងទៀត......

# (១) បញ្ញើជាលក្ខណៈសន្សំ Saving Deposit



# (២).ការរបង្កើតបញ្ញើមានកាលកំណត់នៅធនាគារ Fix Deposit



# (៣) បញ្ញើក្នុងគណនីចរន្ត Current Deposit



# សូមអរគុណ

# សំណួរ-ចម្លើយ

# ៥.ករណីសិក្សា

**អ្នកផ្ញើជាក្រុម (X1-X5)**

**ឃ្លាំង Y ទទួលរក្សាទុក**

X1=ស្រូវសូម៉ាលី 1ton

X3=ស្រូវសូម៉ាលី 1ton

X2=ស្រូវសូម៉ាលី 1ton

X4=ស្រូវសូម៉ាលី 1ton

X5=ស្រូវសូម៉ាលី 1ton




សងវិញនូវប្រភេទសូម៉ាលីដូចគ្នា ចំណែកម្នាក់ៗ តាមសមាមាត្រ

ប៉ុន្តែ X1-X5 មិនព្រមទទួល យកទេ ដោយទាមទារឲ្យ Y សងការខូចខាត ដោយសារ តែ Y បានលក់ស្រូវនេះ

លក់ឲ្យA 3ton

2ខែបន្ទាប់ទិញពី B 3tonវិញ




តើអង្គហេតុខាងលើនេះត្រូវបានចាត់ទុកថាជាកិច្ចសន្យាវិសុណ្ណាប័នឬយ៉ាងណា? ហេតុអ្វី?